ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខៈ ១៤៥ កប/សរ

# សារាចរ
## ស្តីពី
## ប្រាក់ឈ្នួល នៃការងារពេលយប់

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបលោក-លោកស្រី ជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ជ្រាបថា មាត្រា១៣៩ ថ្មី និងមាត្រា១៤៤ ថ្មី នៃច្បាប់ស្តីពីការងារត្រូវបានដាក់អោយប្រើប្រាស់ជាផ្លូវការចាប់ពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧ តទៅ។

ដើម្បីឱ្យដំណើរការអនុវត្តមាត្រាទាំង២នេះ ទទួលបានលទ្ធផលល្អប្រសើរ ធានាបានភាពសុខដុមរមនា រវាងកម្មករនិយោជិត និងនិយោជក ក៏ដូចជាទទួលបានផលិតភាពការងារខ្ពស់ សូមលោក-លោកស្រី ជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិត យកចិត្តទុកដាក់អនុវត្ត ដូចតទៅ :-

១-កម្មករនិយោជិតដែលធ្វើការនៅពេលយប់ ចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ ភ្លឺ ទោះបីធ្វើការផ្លាស់ប្តូរវេនគ្នាក្តី ឬធ្វើការជាអចិន្ត្រៃយ៍ក្តី កម្មករនិយោជិតទាំងនោះត្រូវបានប្រាក់ឈ្នួលស្មើនឹង១៣០%(មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលការងារពេលថ្ងៃ ។ ចំពោះកម្មករនិយោជិតដែលធ្វើការនៅពេលយប់ ហើយទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ តាមការព្រមព្រៀងគ្នារវាងកម្មករនិយោជិត និងនិយោជកកន្លងមកហើយនោះ ត្រូវរក្សាដដែលរហូតចប់សុពលភាព ។

២-សារាចរលេខ ០២៤ សកបយ. ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ព្រមទាំងកម្មករនិយោជិតទាំងអស់ នឹងអនុវត្តតាមខ្លឹមសារសារាចរនេះ បានល្អប្រសើរ ជាពុំខាន។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៧
រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វង សូត

**ចម្លងជូនៈ**
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- -គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ-អនុវត្ត"
- -គ្រប់សមាគមនិយោជក
- -គ្រប់សហព័ន្ធសហជីព "ដើម្បីជ្រាប- អនុវត្ត"
- -កាលប្បវត្តិ-ឯកសារ

អាសយដ្ឋានអគារលេខ ៣, មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់ទឹកល្អក់២, ខ័ណ្ឌទួលគោក, ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារ: (០២៣) ៣៥៣ ៥៣៨៥